# បច្ចេកទេសផលិតកូនបង្កងពូជ ដោយប្រើប្រព័ន្ធទឹកបិទជិត

# Manual for the Seed Production of Giant Freshwater Prawn, *Macrobrachium rosenbergii* using Re-circulated Water System


រៀបរៀងដោយៈ

បណ្ឌិត ស៊ីរ៉ូ ហារ៉ា (Shiro Hara) និងលោក រស់ ឈារិន

ប្រែសម្រួលជាភាសាខ្មែរដោយៈ លោក អ៊ុច ឡុង

កែសម្រួលដោយៈ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល



រក្សាសិទ្ធិដោយៈ នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម



ឆ្នាំ ២០១០

# មាតិកាអត្ថបទ


អារម្ភកថា.....................................................................................................-ខ-
សេចក្តីថ្លែងអំណរគុណ.........................................................................................-ង-
១. ការគ្រប់គ្រងមេពូជ........................................................................................-១-
២. ការភ្ញាស់បង្កង...............................................................................................-៣-
៣. ការថែបំប៉នកូនបង្កងទើបញាស់.........................................................................-៤-
៣.១ ប្រព័ន្ធអាងបំប៉ន.........................................................................................-៤-
ក. ប្រព័ន្ធអាងចម្រោះជីវសាស្ត្រ................................................................................-៥-
ខ. ការរៀបចំប្រព័ន្ធអាងចម្រោះជីវសាស្ត្រ.....................................................................-៧-
៣.២ ការវិវឌ្ឍរបស់កូនបង្កង.....................................................................................-៨-
៣.៣ ដង់ស៊ីតេដាក់បំប៉ន និងការផ្តល់ចំណី.......................................................................-៨-
៣.៤ ការគ្រប់គ្រងគុណភាពទឹក.................................................................................-១៥-
៣.៥ ការប្រមូលផល..............................................................................................-១៧-
៤. ការថែបំប៉នកូនបង្កងដល់ថ្ងៃទី ១៥..........................................................................-១៨-
៤.១ ប្រព័ន្ធអាងបំប៉ន...........................................................................................-១៨-
៤.២ ដង់ស៊ីតេដាក់បំប៉ន ការផ្តល់ចំណី និងការគ្រប់គ្រងគុណភាពទឹក.........-១៨-
៤.៣ ការប្រមូលផល និងដឹកជញ្ជូន.............................................................................-២១-

# អារម្ភកថា

បង្កង *(Macrobrachium rosenbergii)* គឺជាប្រភេទបង្កងដែលត្រូវបានគេទទួលស្គាល់ជាទូទៅថា មានឱជារសឆ្ងាញ់ ហើយមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅលើទីផ្សារពិភពលោក។ ដោយឡែក នៅក្នុងប្រទេសកម្ពុជាយើងវិញ គេសង្កេតឃើញថា បង្កងភាគច្រើនដែលលក់នៅលើទីផ្សារបានមកពីការនេសាទនៅតាមបឹងបួទន្លេ ហើយមានចំនួនតិចតួចបំផុតដែលបានមកពីការចិញ្ចឹម។ បច្ចុប្បន្ននេះ យើងសង្កេតឃើញថា មានកសិករមួយចំនួនទទួលបានជោគជ័យក្នុងការចិញ្ចឹមបង្កងនេះ ប៉ុន្តែកសិករខ្លះក៏កំពុងស្ថិតក្នុងដំណាក់កាលសាកល្បងនៅឡើយ ហើយនៅមានការខ្វះខាតផ្នែកបច្ចេកទេសជាច្រើន។

ម្យ៉ាងទៀត ផ្នែកបច្ចេកទេសផលិតកូនបង្កងពូជវិញ ក៏មានលក្ខណៈថ្មីនៅឡើយ ទើបតែបានចាប់ផ្តើមសកម្មភាពផលិតកម្មកូនពូជរបស់ខ្លួនកាលពីឆ្នាំ ២០០៦។ កន្លងមកគម្រោងបង្កើនផលិតភាព និងផ្សព្វផ្សាយវារីវប្បកម្ម នៃរដ្ឋបាលជលផលបានបញ្ជូនកសិករ និងមន្ត្រីមួយចំនួនឱ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសផលិតកូនបង្កងពូជ" នៅសាកលវិទ្យាល័យ កឹនថឺ នៃប្រទេសវៀតណាម។ នាឆ្នាំដដែលនោះ បន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាលបច្ចេកទេសរួចមក មន្ត្រីបច្ចេកទេស និងជំនាញការជប៉ុន ក៏បានសហការគ្នា ដើម្បីសិក្សាស្រាវជ្រាវបន្ថែមទៀតលើផ្នែកបច្ចេកទេសផលិតកូនបង្កងនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប ខេត្តព្រៃវែងរហូតដល់សម្រេចគោលដៅក្នុងការផលិតកូនបង្កងពូជទទួលបានលទ្ធផលល្អជាមួយនឹងអត្រាគង់វង្សខ្ពស់នៅក្នុងលក្ខខណ្ឌអាកាសធាតុនៃប្រទេសកម្ពុជាយើង។ តាំងពីពេលនោះ ការផលិតកូនបង្កងបានបន្តសកម្មភាពដោយសាកលវិទ្យាល័យភូមិន្ទកសិកម្ម កសិករចំនួនបួននាក់នៅក្នុងខេត្តតាកែវ ម្នាក់នៅខេត្តកំពត

និងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាបនៅបន្តសកម្មភាពសិក្សាស្រាវជ្រាវរបស់ខ្លួនបន្ថែមទៀត ដើម្បីពង្រឹងសមត្ថភាពលើផ្នែកបច្ចេកទេសឱ្យកាន់តែល្អប្រសើរឡើងរហូតមកដល់ឆ្នាំ ២០១០។

គេសង្កេតឃើញថា បង្កងអាចរស់នៅបានស្ទើរពាសពេញគ្រប់ទីកន្លែងទាំងអស់នៅតាមតំបន់ទឹកសាប រហូតដល់ពេលវាធំពេញវ័យទើបវាផ្លាស់ទីទៅតំបន់ទឹកភ្លាវ ដើម្បីពងកូននៅទីនោះ។ បន្ទាប់ពីកូនបង្កងបានញាស់រួច វានឹងបន្តរស់នៅក្នុងតំបន់ទឹកភ្លាវរហូតដល់ធំល្មមក្លាយជាកូនពូជដែលមានអាយុប្រមាណ ១ ខែ ទើបវាហែលត្រឡប់មករស់នៅតាមតំបន់ទឹកសាបវិញ។ អាស្រ័យហេតុនេះទើបតម្រូវឱ្យការងារបច្ចេកទេសផលិតកូនបង្កងពូជអនុវត្តទៅតាមលក្ខខណ្ឌធម្មជាតិផងដែរ។

ជាទូទៅ យើងអាចប្រើប្រាស់បាននូវប្រព័ន្ធអាងជាច្រើនប្រភេទ សម្រាប់ក្នុងការបំប៉នកូនបង្កងទើបតែញាស់ តែអ្វីដែលសំខាន់នោះ គឺការជ្រើសរើសទីតាំងសម្រាប់រៀបចំប្រព័ន្ធអាងបំប៉នកូនបង្កង នៅកន្លែងដែលមានទីតាំងជិតប្រភពទឹកភ្លាវ ឬ ទឹកសមុទ្រ ពោលគឺនៅតាមតំបន់ឆ្នេរសមុទ្រ ពីព្រោះថា កូនបង្កងទើបញាស់ត្រូវការទឹកភ្លាវជាចាំបាច់ ដែលមានកំហាប់អំបិល ១២ ភាគពាន់ សម្រាប់ធ្វើការបំប៉នវា។

ដោយឡែក ចំពោះកសិដ្ឋានបំប៉នកូនបង្កង ឬ កសិដ្ឋានផលិតកូនបង្កងដែលមានទីតាំងឆ្ងាយពីប្រភពទឹកភ្លាវ ឬ ទឹកសមុទ្រ ពោលគឺនៅក្នុងតំបន់ដែនទឹកសាបនោះក៏យើងអាចមានលទ្ធភាពក្នុងការផលិតកូនបង្កងបានដែរ តាមរយៈការប្រើប្រាស់ប្រព័ន្ធទឹកបៃតងដែលបានសិក្សាស្រាវជ្រាវរកឃើញដោយមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិជប៉ុន (JIRCAS) សហការជាមួយសាកលវិទ្យាល័យ កឺនថឺ នៃប្រទេសវៀតណាម ហើយប្រព័ន្ធទឹកបៃតងនេះ ត្រូវបាននិងកំពុងប្រើប្រាស់ ដោយកសិករមួយចំនួននៅក្នុងខេត្តតាកែវ។ ថ្វីត្បិតតែប្រព័ន្ធទឹក

បែតងនេះ  អាចប្រើប្រាស់បានក្នុងការផលិតកូនបង្កងយ៉ាងណាក៏ដោយតែបញ្ហាប្រឈមនៅតែកើតមានឡើងចំពោះកសិករ  ជាពិសេសបញ្ហាការថែរក្សារុក្ខជាតិបួង់តុង  ក្លរ៉េល្លា  នៅក្នុងអាងបំប៉នកូនបង្កងដែលជាមូលហេតុបង្កឱ្យកូនបង្កងមានជំងឺ។  អាស្រ័យដោយមានបញ្ហាជួបប្រទះដូចបានជម្រាបជូនខាងលើបានធ្វើឱ្យក្រុមអ្នកបច្ចេកទេសយើងខ្ញុំ  នៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ  និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាបខិតខំសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើបច្ចេកទេសដែលមានលក្ខណៈល្អសមស្របអាចប្រើប្រាស់បានក្នុងការផលិតកូនបង្កងប្រកបដោយជោគជ័យ ។

នៅក្នុងឯកសារបច្ចេកទេសនេះ  ក្រុមអ្នកបច្ចេកទេសយើងខ្ញុំនឹងធ្វើការបកស្រាយបង្ហាញជូននូវបច្ចេកទេសថ្មីមួយផ្សេងទៀត  ក្នុងការផលិតកូនបង្កងប្រកបដោយជោគជ័យដោយប្រើប្រាស់នូវប្រព័ន្ធទឹកបិទជិត (Re-circulation system) ដែលថែមទាំងអាចជួយកាត់បន្ថយការប្រើប្រាស់ទឹកសមុទ្របាន  និងគ្មានបញ្ហាជំងឺកកើតឡើង។  ប្រព័ន្ធនេះអាចមានលទ្ធភាពផលិតកូនបង្កងបានចំនួន ៦០.០០០ ក្បាលកូនម្សៅនៅក្នុងចំណុះទឹក ១,៥ ម៉ែត្រគុប ។

បច្ចេកទេសថ្មីដែលនឹងធ្វើការបកស្រាយជូននៅក្នុងឯកសារនេះ  បានមកពីកិច្ចសហប្រតិបត្តិការខិតខំសិក្សាស្រាវជ្រាវបន្ថែម  ធ្វើឱ្យកាន់តែល្អប្រសើរឡើងរវាងរដ្ឋបាលជលផល  នៃក្រសួងកសិកម្ម  រុក្ខាប្រមាញ់  និងនេសាទ  និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ។

យើងខ្ញុំទាំងអស់គ្នា  សង្ឃឹមថាឯកសារបច្ចេកទេសថ្មីនេះនឹងអាចជួយដល់អស់លោកអ្នកបាននៅក្នុងការផលិតកូនបង្កងប្រកបដោយជោគជ័យ  និងលទ្ធផលល្អហើយជួយជំរុញបន្ថែមទៀតការអភិវឌ្ឍវារីវប្បកម្មនៅក្នុងប្រទេសកម្ពុជាយើង ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **ឈៅ ឆួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានជួយជ្រោមជ្រែងលើកទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវឱ្យមានដំណើរការល្អ និងទទួលបានជោគជ័យ ។

យើងខ្ញុំ សូមថ្លែងអំណរគុណផងដែរ ចំពោះមន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម និងលោក **ខ៉ាន់ ហេង** ប្រធាន និងលោក **សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប រួមទាំងមន្ត្រីទាំងអស់ដែលបានចូលរួមក្នុងសកម្មភាពការងារគម្រោង និងការសិក្សាស្រាវជ្រាវនេះ ព្រមទាំងលោក **Satoshi Chikami** លោក **Yoshitetsu Nukiyama** ប្រធានទីប្រឹក្សាគម្រោងបង្កើនផលិតភាព និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប (FAIEX Project/JICA) ដែលបានដឹកនាំអនុវត្តគម្រោងប្រកបដោយភាពរលូន និងទទួលបានជោគជ័យ ។

ឯកសារស្តីពីបច្ចេកទេសផលិតកូនបង្កងពូជនេះ ត្រូវបានរៀបចំចងក្រងលេចចេញជារូបរាងឡើង អាស្រ័យដោយមានការជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុរបស់អង្គការចៃកា (JICA) ។

ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០

បណ្ឌិត**ស៊ីរ៉ូ ហារ៉ា (Shiro Hara)**

មន្ត្រីបច្ចេកទេសស្ម័គ្រចិត្តជាន់ខ្ពស់

អង្គការចៃកា (JICA)

## ១. ការគ្រប់គ្រងមេពូជ

បង្កងមេពូជធម្មជាតិដែលពេញវ័យល្អអាចយកមកភ្ញាស់បាន មានប្រភពមកពីការនេសាទពីទន្លេនៅក្នុងខេត្តពីរសំខាន់គឺខេត្តតាកែវ និងព្រៃវែង។ ដោយឡែកនៅតាមតំបន់ ឬ ក៏ខេត្តផ្សេងទៀត យើងអាចរកមេពូជបង្កងមកភ្ញាស់បានតាមរយៈការរកទិញពីកសិករដែលពួកគាត់ចិញ្ចឹមយកសាច់នៅក្នុងស្រះ ឬ ម្យ៉ាងទៀតយើងអាចធ្វើការជ្រើសរើសមេពូជចេញពីបង្កងសាច់ ដែលយើងចិញ្ចឹមដោយផ្ទាល់ខ្លួនឯងតែម្តង។ ករណីនៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាបវិញ យើងបានប្រើប្រាស់មេពូជទិញមកពីភោជនីយដ្ឋាននៅក្នុងតំបន់កំពង់ចម្លងអ្នកលឿង ដែលជាទីកន្លែងមួយសម្បូរទៅដោយមេពូជបង្កងល្អៗ ហើយអាចរកទិញបាននៅគ្រប់ពេលវេលាក្នុងអំឡុង ខែ មិថុនា ដល់ ខែ កញ្ញា។ យើងគួរជ្រើសរើសមេពូជដែលពេញវ័យ មានសុខភាព និងលក្ខណៈដងខ្លួនល្អ មិនតែប៉ុណ្ណោះក៏មានគ្រាប់ពងពណ៌ត្នោតក្រម៉ៅ ហើយមានឃើញលេចចេញនូវគ្រាប់ភ្នែករបស់កូនបង្កង (រូបភាពទី ១) អាចយកវាមកភ្ញាស់បានក្នុងរយៈពេលពី ១ ថ្ងៃ ទៅ ៣ ថ្ងៃបន្ទាប់នៅក្នុងប្រព័ន្ធអាងភ្ញាស់។ ចំពោះមេពូជដែលមានគ្រាប់ពងពណ៌ទឹកក្រូច ឬ លឿង (រូបភាពទី ២) វិញនោះ យើងអាចយកវាមកភ្ញាស់បាននៅក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ក្នុងលក្ខខណ្ឌសីតុណ្ហភាពពី ២៧ ទៅ ៣០ អង្សាសេ នៅក្នុងប្រព័ន្ធអាងភ្ញាស់។



រូបភាពទី១: គ្រាប់ពងពណ៌ត្នោតក្រមៅ



រូបភាពទី២: គ្រាប់ពងពណ៌ទឹកក្រូច

ក្នុងករណីការភ្ញាស់បង្កងត្រូវបានពន្យារពេល យើងត្រូវផ្តល់ចំណីបន្ថែមដល់មេពូជ ដែលកំពុងត្រៀមបម្រុងដាក់ភ្ញាស់នោះភ្លាម ដោយឱ្យវាស៊ីសាច់កំពឹសស្រស់ ឬចំណីគ្រាប់ក្នុង ១ ថ្ងៃម្តងនៅពេលរសៀលត្រជាក់ ពីព្រោះថា នៅពេលវាឃ្លានចំណីនោះវានឹងស៊ីគ្រាប់ពងរបស់វា។ ការផ្តល់ចំណីនេះនឹងត្រូវបានបញ្ឈប់វិញ នៅពេលដែលគ្រាប់ពងបានឈានដល់ដំណាក់កាលប្រែទៅជាពណ៌ត្នោត ហើយមានឃើញលេចចេញនូវគ្រាប់ភ្នែករបស់កូនបង្កង ដែលខណៈពេលនោះយើងត្រូវផ្ទេរមេពូជពីទឹកសាបដាក់ចូលទៅក្នុងប្រព័ន្ធអាងភ្ញាស់មានទឹកភ្លាវដែលមានកំហាប់អំបិល ៦ ភាគពាន់ ដោយឡែកនៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប វិញយើងបានរៀបចំត្រៀមបម្រុងមេពូជសម្រាប់ភ្ញាស់នៅក្នុងអាង ដែលមានចំណុះ ៣០ លីត្រ ដោយបញ្ចូលទឹកសាបចំណុះ ១៥ លីត្រ និងបញ្ចូលខ្យល់ជាប់ជាប្រចាំនូវកម្រិតដង់ស៊ីតេមេពូជចំនួន ១ក្បាលក្នុងអាង។ អាងស្តុកមេពូជបម្រុងសម្រាប់ភ្ញាស់នេះត្រូវធ្វើការផ្លាស់ប្តូរទឹកថ្មីជាប្រចាំនូវកម្រិត ៨០ ភាគរយ ក្នុងមួយថ្ងៃរហូតដល់ថ្ងៃដំណើរការចាប់មេពូជដាក់ភ្ញាស់។

**ប្រភពទឹកប្រៃ:** ទឹកប្រៃមានប្រភពសំខាន់ដឹកជញ្ជូនមកពីស្រែអំបិល នៅក្នុងខេត្តកំពត។ ទឹកប្រៃនេះ មានកម្រិតកំហាប់អំបិលប្រមាណ ៨០ ភាគពាន់ វាស់

ដោយឧបករណ៍វាស់កំហាប់អំបិល (Salinity meter)។ ទឹកប្រៃក្រោយពីបានដឹកជញ្ជូនមកពីស្រែអំបិល រួចយើងត្រូវរៀបចំដាក់វាស្តុកនៅក្នុង អាងស៊ីម៉ង់ត៍ ឬ អាងអេស អ័រ ភី (FRP) ដោយមានគម្របបិទជិតដើម្បីការពារធូលី សត្វល្អិត និងសម្រាមផ្សេងៗចូលទៅក្នុងអាងធ្វើឱ្យខូចគុណភាពទឹក។

## ២. ការភ្ញាស់បង្កង

ជាទូទៅ បង្កងត្រូវបានគេរៀបចំភ្ញាស់នៅពេលយប់ ហើយធ្វើការប្រមូលកូនញាស់ នៅពេលព្រឹកនាថ្ងៃស្អែកបន្ទាប់។ មេបង្កងមួយចំនួនអាចភ្ញាស់កូនបានអស់តែក្នុងរយៈពេលមួយយប់តែប៉ុណ្ណោះ តែមួយចំនួនផ្សេងទៀតអាចភ្ញាស់កូនបានក្នុងរយៈពេលវែងជាងនេះ គឺចាប់ពី ១ ទៅ ២ យប់ទើបកូនញាស់អស់ អាស្រ័យដោយការវិវឌ្ឍរបស់គ្រាប់ពងដល់ដំណាក់កាលទុំពេញវ័យខុសៗគ្នា។ រីឯចំនួនកូនដែលបានញាស់វិញអាស្រ័យដោយទំហំ ឬ ទម្ងន់មេពូជនីមួយៗ។ ទំនាក់ទំនងគ្នារវាងចំនួនកូនញាស់ (Y) ជាមួយនឹងទម្ងន់មេពូជ (X) គឺត្រូវបានគេធ្វើការបកស្រាយបង្ហាញតាមរយៈរូបមន្តខាងក្រោមនេះ:

Y= ៩៩៩X - ១៥,០៨៧

ឧទាហរណ៍:

-បង្កងមួយក្បាល ទម្ងន់ ៣០ ក្រាម អាចភ្ញាស់កូនបានចំនួន ១៥.០០០ ក្បាល

-បង្កងមួយក្បាល ទម្ងន់ ៥០ ក្រាម អាចភ្ញាស់កូនបានចំនួន ៤៩.០០០ ក្បាល

-បង្កងមួយក្បាល ទម្ងន់ ១០០ក្រាម អាចភ្ញាស់កូនបានចំនួន ៨៥.០០០ ក្បាល

កូនបង្កង ដែលទើបញាស់ ត្រូវបានគេប្រមូល វាដោយប្រើកន្ត្រងយកទៅធ្វើអនាម័យនៅក្នុងចានដែកឬ ចានជ័រមួយដែលមានល្បាយទឹកភ្លាវមានកំហាប់អំបិល ៦ ភាគពាន់ លាយជាមួយនឹងហ្វ័រម៉ាលីន ២០០ មិល្លីក្រាមក្នុង ១ លីត្រទឹក (រូបភាព

ទី ៣)។ ការធ្វើអនាម័យនេះត្រូវបានធ្វើឡើងដោយត្រាំកូនបង្កងនៅក្នុងល្បាយទឹកភ្លាវដែលលាយជាមួយនឹងហ្វ័រម៉ាលីន ដូចបានជម្រាបជូនខាងលើនៅក្នុងរយៈពេលប្រមាណ ៣០ វិនាទីរួចយកវាទៅសម្អាតនឹងល្បាយទឹកភ្លាវ ៦ ភាគពាន់មុនពេលលែងចូលទៅក្នុងអាងបំប៉នកូនបង្កងដែលមានល្បាយទឹកភ្លាវ ១២ ភាគពាន់បានរៀបចំរួចជាស្រេច។



រូបភាពទី៣: ការធ្វើអនាម័យកូនបង្កង

យើងបានសង្កេតឃើញថា កូនបង្កងភាគច្រើនបានអណ្តែតនៅលើផ្ទៃទឹកក្រោយពេលលែងចូលអាងបំប៉នរួចមក អាស្រ័យដោយមានការប្រែប្រួលលឿនពេករវាងកំហាប់អំបិលនៅក្នុងអាងភ្លាស់ ៦ ភាគពាន់ និងអាងបំប៉ន ១២ ភាគពាន់ តែកូនបង្កងនឹងមានសុខភាពល្អប្រសើរឡើងវិញ បន្ទាប់ពីបានលែងចូលអាងបំប៉ននោះរយៈពេលមួយថ្ងៃក្រោយមក។

## ៣. ការថែបំប៉នកូនបង្កងទើបញាស់

### ៣.១ ប្រព័ន្ធអាងបំប៉ន

រាល់ឧបករណ៍ សំភារៈចាំបាច់សម្រាប់ប្រើប្រាស់ក្នុងការបំប៉នកូនបង្កងទាំងអស់ដូចជាប្រព័ន្ធអាងបំប៉នកូនបង្កង និងប្រព័ន្ធអាងចម្រោះជីវសាស្ត្រត្រូវតែរៀបចំព័ទ្ធសំពត់ខៀវដាក់នៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ និងរក្សាបាននូវសីតុណ្ហភាពឱ្យមានស្ថេរភាពល្អ ហើយម្យ៉ាងទៀតត្រូវតែធ្វើអនាម័យឱ្យបានស្អាតល្អនូវរាល់ឧបករណ៍សំភារៈទាំងនេះដោយប្រើប្រាស់ ២០០ មិល្លីក្រាមក្នុង ១ លីត្រទឹក មេសាប៊ូ (Liquid bleach) (មេសាប៊ូ ឬ ក្លរីន ៦ ភាគរយ ៣៣ មិល្លីលីត្រ/១០ លីត្រទឹក) មុនពេលប្រើប្រាស់។

## ក. ប្រព័ន្ធអាងចម្រោះជីវសាស្ត្រ

ប្រព័ន្ធអាងចម្រោះនេះ រួមមាន ៣ ប្រព័ន្ធអាងចម្រោះជីវសាស្ត្រ (G&H: 160L; I:120L),Protein skimmer (J) និងប្រព័ន្ធ អាងបំប៉នចំនួន៣ (K,L,M : 600L) ដូចបានបង្ហាញក្នុងរូបភាពទី ៤ និងគំនូសតាងទី ១ ប្រព័ន្ធអាងចម្រោះជីវសាស្ត្រនេះ ប្រើប្រភេទថ្មតូចទំហំ ១ សង់ទីម៉ែត្រ និងបំពង់ជ័រខ្មៅកាត់ជាកំណាត់ក្រោលមានប្រវែង ២ សង់ទីម៉ែត្រ ។



**រូបភាពទី៤: ចម្រោះជីវសាស្ត្រ**

ប្រព័ន្ធអាងចម្រោះជីវសាស្ត្រនេះ មានតួនាទីយ៉ាងសំខាន់នៅក្នុងការបង្ហូរទឹកអាហ្សូត (Nitrogen) យកចេញមកខាងក្រៅដែលទឹកនេះមានប្រភពកកើតឡើងមកពីឧស្ម័នអាម៉ូញាក់ដែលបង្កឡើងដោយកាកសំណល់បញ្ចេញចោលរបស់កូនបង្កង និងកាកសំណល់សរីរាង្គរលួយផ្សេងៗទៀត ។




រូបភាពទី១: ការរៀបចំប្រព័ន្ធអាង ចម្រោះជីវសាស្ត្រសម្រាប់ផ្គត់ផ្គង់ទឹកបំប៉នកូនត្រី

A: ចរន្តទឹកហូរ

B: ម៉ូទ័របូមទឹក

C: ថ្មខ្យល់

D: ថ្មគ្រួស ឬថ្មល្អិតតូចៗ

E: កំណាត់បំពង់ជ័រ

F: វ៉ានមូលទឹក

G-I-H: ប្រព័ន្ធអាងចម្រោះជីវសាស្ត្រ

J: ប្រូតេអ៊ីនស្គីមឺរ (Protein skimmer)

ប្រូតេអ៊ីនស្គីមឺរ (Protein skimmer) ជាឧបករណ៍មួយត្រូវបានគេយកវាមកប្រើប្រាស់សម្រាប់ប្រមូលយកចេញនូវរាល់កាកសំណល់សរីរាង្គតូចៗ ដោយប្រើពពុះខ្យល់ដែលបង្កើតឡើងដោយកម្លាំងសម្ពាធទឹកផ្សំជាមួយនឹងការបញ្ចូលខ្យល់។

## ខ. ការរៀបចំប្រព័ន្ធអាងចម្រោះជីវសាស្ត្រ

ចម្រោះជីវសាស្ត្រនេះ ត្រូវបានគេដំឡើង និងរៀបចំឱ្យដំណើរការជាមុនរួចជាស្រេចមុនពេលប្រើប្រាស់ក្នុងប្រព័ន្ធអាងបំប៉នកូនបង្កងប្រមាណរយៈពេលមួយខែមុន។ នៅក្នុងប្រព័ន្ធអាងចម្រោះនេះ យើងបានប្រើប្រាស់សារធាតុគីមីម៉្យាងឈ្មោះ អាម៉ូញ៉ូមក្លរាយ ($NH_4Cl$) សម្រាប់ជួយជំរុញការវិវដ្តលូតលាស់របស់ពពួកបាក់តេរី។ ជាដំបូង យើងប្រើអាម៉ូញ៉ូមក្លរាយ ($NH_4Cl$) ចំនួន ៤០ មិល្លីក្រាមក្នុង ១ លីត្រទឹក រំលាយបញ្ចូលទៅក្នុងទឹកដែលមានកំហាប់អំបិល ១២ ភាគពាន់ ចំណុះ ១៣០ លីត្រក្នុង អាងចម្រោះជីវសាស្ត្រទាំងពីរ គឺអាង G និង H ហើយប្រើប្រាស់វត្ថុធាតុដើម (ថ្មតូចៗ) មួយចំនួនសម្រាប់ធ្វើជាជម្រក។ ខណៈពេលនោះ បរិមាណអាម៉ូញ៉ូមក្លរាយត្រូវស្រូបយកអស់ដោយពពួកបាក់តេរី ហើយឧស្ម័នអាម៉ូញ៉ាក់មានចំនួនកើនឡើងទ្វេដង(៨០ មិល្លីក្រាមក្នុង ១ លីត្រទឹក)។




រូបភាពទី៩: ឧបករណ៍វាស់អាម៉ូញ៉ាក់ និងនីទ្រីត

ហើយជាចុងក្រោយ យើងបានបន្ថែមនូវបរិមាណអាម៉ូញ៉ូមក្លរាយ ($NH_4Cl$) ចំនួន ១៨០ មិល្លីក្រាមក្នុង ១ លីត្រទឹកបន្តទៀត។ បន្ទាប់មកទៀតយើងធ្វើការតាមដាន និងត្រួតពិនិត្យជាប្រចាំនូវរាល់ពពួកឧស្ម័នមួយចំនួនដែលកើតឡើង ដូចជាឧស្ម័ន

អាម៉ូញាក់ និងនីទ្រីតដោយប្រើឧបករណ៍តេសឃីត (Ammonium and Nitrite-test kits) (រូបភាពទី ៥) ។

យើងសម្រេចចិត្តសាកល្បង បន្ថែមអាម៉ូញ៉ូមក្លរាយនៅលើកទី ២ និង ទី ៣ បន្តទៀតនៅពេលដែលសង្កេតឃើញថាឧស្ម័នអាម៉ូញូម និងនីទ្រីតត្រូវបានប្រើប្រាស់អស់ដោយពពួកបាក់តេរី ។ យើងបានចាប់ផ្តើមដំណើរការប្រតិបត្តិប្រព័ន្ធអាងចម្រោះជីវសាស្ត្រនេះ នៅពេលដែលកូនបង្កងបានឈានដល់ដំណាក់កាលទី ១ ឬ ទី ៤ នៅក្នុងអាងបំប៉ន ដែលមានកម្រិតចរន្តទឹកហូរពី ៥០០ ទៅ ៨០០ មិល្លីលីត្រក្នុង ១នាទី ។

## ៣.២ ការវិវឌ្ឍរបស់កូនបង្កង

ការវិវឌ្ឍរបស់កូនបង្កងទាំង ១២ ដំណាក់កាល ដូចបានបង្ហាញជូនស្រាប់តាមរយៈរូបភាពទី ២ **A** និងទី ២ **B** និងតារាងទី ១ ។

## ៣.៣ ដង់ស៊ីតេដាក់បំប៉ន និងការផ្តល់ចំណី

ដង់ស៊ីតេកូនបង្កងទើបញាស់ ដែលសមស្របបំផុត សម្រាប់បំប៉ននៅក្នុងអាងបំប៉នគួរដាក់ចំនួន ៦០ . ០០០ ក្បាលក្នុង ១ ម៉ែត្រគុបទឹក។ ដោយឡែក នៅក្នុងប្រព័ន្ធបិទជិត យើងបានដាក់កូនបង្កងបំប៉នចំនួន ៧០.០០០ ក្បាលក្នុង ១ ម៉ែត្រគុបទឹក ហើយបំប៉នក្នុងរយៈពេល ៣៥ ថ្ងៃ គិតចាប់ពីកូនទើបញាស់រហូតដល់ដំណាក់កាលកូនមេ្យា (Post-larvae) ។ ចំពោះការផ្តល់ចំណីវិញ យើងបានប្រើប្រាស់ចំណីបីប្រភេទ គឺអាតេមីញ៉ាចំណីផ្សំ (ផ្សំដោយផ្ទៃកក្រហមពងមាន់ និងមេ្យាទឹកដោះគោ) និងចំណីគ្រាប់ ឬ ចំណីរោងចក្រដោយផ្តល់ឱ្យកូនបង្កងស៊ីនូវចំណីទាំងបីប្រភេទខាងលើនេះមានការផ្លាស់ប្តូរប្រភេទចំណីខុសៗគ្នា ទៅតាមដំណាក់កាលលូតលាស់របស់កូនបង្កង។ សេចក្តីសង្ខេបពីការផ្តល់ចំណីទាំងបីប្រភេទដល់កូនបង្កង ដូចបានជម្រាបជូនតាមរយៈតារាងទី ២ និងទី ៣ ខាងក្រោមនេះ។



ដំណាក់កាលទី ១



ដំណាក់កាលទី ២



ដំណាក់កាលទី ៣



ដំណាក់កាលទី ៤



ដំណាក់កាលទី ៥



ដំណាក់កាលទី ៦

**រូបភាពទី២ A: ការវិវដ្តរបស់កូនបង្កងចាប់ពីដំណាក់កាលទី ១ ដល់ដំណាក់កាលទី ៦**



ដំណាក់កាលទី ៧



ដំណាក់កាលទី ៨



ដំណាក់កាលទី ៩



ដំណាក់កាលទី ១០



ដំណាក់កាលទី ១១



ដំណាក់កាលម្សៀ PL

**រូបភាពទី២ B: វិវឌ្ឍរបស់កូនបង្កងចាប់ពីដំណាក់កាលទី ៧ ដល់ដំណាក់កាលទី ១២**

## តារាងទី ១ លក្ខណៈកូនបង្កងទាំង ១២ ដំណាក់កាល

| ដំណាក់កាលវិវត្ត របស់កូនបង្កង | លក្ខណៈកូនបង្កង |
|---|---|
| ១ | គ្មានទងភ្នែក |
| ២ | មានទងភ្នែក |
| ៣ | កន្ទុយលេចចេញជារូបរាង (Uropods) |
| ៤ | មានដុះធ្មេញរណារពីរនៅលើឆ្អឹងច្រមុះ (Rostrum) |
| ៥ | តែលសូន (Telson) តូចស្ដួចរាងវែង |
| ៦ | ពន្លកជើងក្រោមពោះ (Pleopods) ដុះចេញជារូបរាង |
| ៧ | ជើងក្រោមពោះដុះបែកខ្នែងជាពីរ |
| ៨ | ជើងក្រោមពោះមានដុះរោមជាច្រើន |
| ៩ | ជើងក្រោមពោះផ្នែកខាងក្នុងមានដុះបែកជាខ្នែង |
| ១០ | មានដុះធ្មេញរណារចំនួនបី ឬ បួននៅលើឆ្អឹងច្រមុះ (Rostrum) |
| ១១ | មានដុះធ្មេញរណារប្រមាណ ៥០ ភាគរយ នៅលើឆ្អឹងច្រមុះ (Rostrum) |
| ១២ | មានដុះធ្មេញរណារនៅទាំងផ្នែកលើ និងក្រោមឆ្អឹងច្រមុះ (Rostrum) |

## តារាងទី ២ ការផ្តល់ចំណីដល់កូនបង្កង ៣៥.០០០ ក្បាល នៅក្នុងអាងទំហំ ០.៥ ម៉ែត្រគុប ដោយប្រើអាតេមីញ៉ា

| ដំណាក់កាលកូនបង្កង | អាយុកូនបង្កង (ថ្ងៃ) | បរិមាណអាតេ - មីញ៉ា (ក្រាម) | ការផ្តល់ចំណី (ដង/ថ្ងៃ) | ពេលវេលាផ្តល់ចំណីម៉ោង |
|---|---|---|---|---|
| ២-៤ | ២-៧ | ២.៥ | ២ | ៧:៣០<br>១៧:០០ |
| ៥-កូនមេប្បា | ៨-៣៥ | ២.៥-៣,៥ | ១ | ១៧:០០ |

## តារាងទី ៣ ការផ្តល់ចំណីដល់កូនបង្កង ៣៥.០០០ ក្បាល នៅក្នុងអាងទំហំ ០.៥ ម៉ែត្រគុប ដោយប្រើចំណីផ្សំ

| ដំណាក់កាលកូនបង្កង | អាយុកូនបង្កង(ថ្ងៃ) | ទំហំ កញ្រ្ចែងចំណី(មីក្រូម៉ែត្រ) | បរិមាណចំណី (ក្រាម) | ការផ្តល់ចំណី (ដង/ ថ្ងៃ) | ពេលវេលាផ្តល់ចំណីម៉ោង |
|---|---|---|---|---|---|
| ៤-៥ | ៧-១០ | ៣០០ | ៣ | ៤ | ៧:៣០<br>១១:០០<br>១៤:០០<br>១៧:០០ |
| ៦-៨ | ១១-២២ | ៥០០ | ៤-៦.៤ | ៤ | ដូចខាងលើ |
| ៩-កូនមេប្បា | ២៣-៣៥ | ៧០០ | ៧.២-៨.៨ | ៤ | ដូចខាងលើ |

កូនបង្កងក្រោយពីញាស់បានមួយថ្ងៃ មិនចាំបាច់ផ្តល់ចំណីឱ្យវាស៊ីនោះទេ។ ការផ្តល់ចំណីដល់កូនបង្កងត្រូវបានចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី ២ បន្ទាប់ពីញាស់។ ការផ្តល់ចំណីនៅលើកដំបូង ដោយផ្តល់កូនអាតេមីញ៉ា ភ្ញាស់រយៈពេល ១២ ម៉ោង (ដែលគេហៅថាដំណាក់កាលទូលផ័ត្ររូបភាព ទី ៦) ដល់កូនបង្កងស៊ីចាប់ពីថ្ងៃទី ២ ដល់ទី ៧ បន្ទាប់ពីញាស់ (កូនបង្កងដំណាក់កាលទី ៤) នូវបរិមាណអាតេមីញ៉ា ២,៥ ក្រាមក្នុង១ថ្ងៃ ផ្តល់ចំនួនពីរដងគឺនៅពេលព្រឹកម៉ោង ៧ និងល្ងាច ម៉ោង ៥។



**រូបភាពទី៦: កូនអាតេមីញ៉ាភ្ញាស់រយៈពេល ១២ ម៉ោងក្នុង ១ ម៉ែត្រគុប**

កូនបង្កងមានអាយុចាប់ពី ៨ ថ្ងៃឡើងទៅ យើងផ្តល់ចំណីពីរប្រភេទគឺ ចំណីកាស្តាត[១] និងកូនអាតេមីញ៉ាភ្ញាស់រយៈពេល ២៤ ម៉ោង។ ចំពោះចំណីកាស្តាតផ្តល់ឱ្យកូនបង្កង ៣៥.០០០ ក្បាលស៊ីចំនួនបួនដងក្នុងមួយថ្ងៃ គឺនៅម៉ោង ៧:៣០ ព្រឹក ម៉ោង ១១:០០ ថ្ងៃត្រង់ ម៉ោង ២ រសៀល និងម៉ោង ៥ ល្ងាច នូវបរិមាណចំណី ៣ ក្រាម ហើយបរិមាណកូនអាតេមីញ៉ាចាប់ពី ៥ ទៅ ៧ ក្រាម ចំនួនមួយដងក្នុងមួយថ្ងៃ គឺនៅម៉ោង ៥ ល្ងាច។ មុនពេលផ្តល់ចំណីម្តងៗ យើងគួរគប្បីផ្តាច់ចរន្តខ្យល់មួយរយៈពេលខ្លីសិន ដើម្បីរង់ចាំកូនបង្កងប្រមូលផ្តុំគ្នា លើផ្ទៃទឹកនៅតាមជញ្ជាំងអាងរួចដំណើរការផ្តល់ចំណីដល់វា នោះទើបជាការល្អប្រសើរ។ ចំពោះចំណីគ្រាប់ (ជាប្រភេទចំណីគ្រាប់លិចទឹកមានកម្រិតប្រូតេអ៊ីន ៤០ ភាគរយ) វិញក៏យើងត្រូវចាប់ផ្តើមឱ្យកូនបង្កងស៊ីផងដែរ គឺចាប់ផ្តើមឱ្យវាស៊ីនៅក្នុងដំណាក់កាលកូនម្សៅនៅក្នុងរយៈពេលមួយសប្តាហ៍មុនពេលប្រមូលផល។

*(១.កាស្តាត: ផ្សំឡើងដោយផ្នែកលឿងនៃស៊ុតមាន់ ឬ ទាជាមួយម្សៅទឹកដោះគោ)*

យើងដឹងហើយថា ការផ្តល់ចំណីផ្សំតែងតែបង្កឱ្យមានភាពកខ្វក់ ខូចគុណភាពទឹកនៅក្នុងអាង ហើយអាចមានផលប៉ះពាល់មិនល្អដល់កូនបង្កងដែលបង្កឡើងដោយពពួកមេរោគធ្វើឱ្យអត្រាបាត់បង់ខ្ពស់ ឬអត្រាគង់វង្សទាប ។ អាស្រ័យហេតុ នេះ យើងត្រូវរកវិធីដោះស្រាយឱ្យបានល្អសមស្របនៅក្នុងការផ្តល់ចំណីផ្សំនេះ ។ តាមរយៈបទពិសោធន៍ល្អទទួលបានកន្លងមក យើងធ្វើការផ្តល់ចំណីដល់កូនបង្កងតាមវិធីសាស្ត្រដូចខាងក្រោមនេះក្នុងករណីដង់ស៊ីតេកូនបង្កងដាក់បំប៉ន ៧០ ក្បាលក្នុង១លីត្រទឹកនោះ យើងត្រូវផ្តល់ចំណីផ្សំ:

- កូនបង្កងអាយុចាប់ពី ៧ ថ្ងៃ ទៅ ១០ ថ្ងៃ ផ្តល់ចំណី ០,៧៥ ក្រាម ក្នុងមួយថ្ងៃចំនួន ៤ ដង (ទំហំចំណី ០,៣ មិល្លីម៉ែត្រ)
- កូនបង្កងអាយុចាប់ពី ១១ ថ្ងៃ ទៅ ២២ ថ្ងៃ ផ្តល់ចំណី ១-១,៦ ក្រាម ក្នុងមួយ ថ្ងៃ ចំនួន ៤ ដង (ទំហំចំណី ០,៥ មិល្លីម៉ែត្រ)
- កូនបង្កងអាយុចាប់ពី ២៣ ថ្ងៃ ទៅ ៣៥ថ្ងៃ ផ្តល់ចំណី ១,៨-២,២ ក្រាម ក្នុងមួយថ្ងៃ ចំនួន ៤ ដង (ទំហំចំណី ០,៧ មិល្លីម៉ែត្រ) ។

ដោយឡែក ចំពោះចំណីគ្រាប់វិញ យើងផ្តល់ឱ្យកូនបង្កងស៊ីនូវបរិមាណចាប់ពី ១ ទៅ ១,៥ ក្រាម ក្នុងមួយថ្ងៃចំនួន ៣ ដង នៅក្នុងដំណាក់កាលកូនម្សៅ នៅក្នុងរយៈពេលមួយសប្តាហ៍មុនពេលប្រមូលផល ។ ការផ្តល់ចំណីផ្សំតាមវិធីសាស្ត្រខាងលើនេះ យើងបានសង្កេតឃើញថា បញ្ហាកខ្វក់នៃទឹកមិនដែលបង្កឡើងនៅក្នុងអាងបំប៉នកូនបង្កងនោះឡើយ ។

ប្រការដែលសំខាន់មួយទៀត នៅក្នុងដំណាក់កាលចុងក្រោយនេះ យើងគួរគប្បីបង្អត់ចំណីកូនបង្កងមួយថ្ងៃមុនពេលធ្វើការប្រមូលផល ។

**ចំណាំ:**

- **ការភ្ញាស់អាតេមីញ៉ា:** គួរថ្លឹងអាតេមីញ៉ា ២ ក្រាម រួចដាក់វាភ្ញាស់នៅក្នុងទឹកភ្លាវ ១២ ភាគពាន់ ចំណុះ ១ លីត្រ
- **ការធ្វើអនាម័យកូនអាតេមីញ៉ា:** កូនអាតេមីញ៉ាទើបញាស់ត្រូវបានធ្វើអនាម័យឱ្យស្អាតល្អដោយប្រើល្បាយហ្វ័រម៉ាលីន ២០០ មិល្លីក្រាមក្នុង ១ លីត្រទឹក (៦០ មិល្លីលីត្រ ក្នុង ១០ លីត្រ) រយៈពេល ១ នាទី រួចលាងសំអាតឡើងវិញដោយទឹកភ្លាវ ១២ ភាគពាន់ មុនពេលផ្តល់ឱ្យកូនបង្កងស៊ី។
- **វិធីសាស្រ្តផ្សំចំណី:** ជាដំបូងយកផ្នែកក្រហមពងមាន់ចំនួន ១០ គ្រាប់ និងម្សៅទឹកដោះគោ ១០០ ក្រាម រួចថ្លឹងទម្ងន់សរុប នៃធាតុផ្សំទាំងពីរនេះ។ បន្ទាប់មកលាយបញ្ចូលប្រេងមឹក ៣ ភាគរយ លីស៊ីទី ១.៥ ភាគរយ វីតាមីនសេ 0.១ ភាគរយ និងថែមទឹក ៥០ មិល្លីលីត្រ និងទឹកល័ក្ខបន្តិចហើយកូរលាយបញ្ចូលគ្នានៅក្នុងម៉ាស៊ីនទឹក ក្រឡុករួចដាក់វាចំហុយនៅក្នុងឆ្នាំង ១៥នាទី។ ចំណីផ្សំនេះក្រោយពីចំហុយរួច យើងកាត់វាជាចំណែកតូចៗ ហើយយកវាទៅរក្សាទុកក្នុងទូទឹកកកសម្រាប់ផ្តល់ឱ្យកូនបង្កងស៊ី។

## ៣.៤ ការគ្រប់គ្រងគុណភាពទឹក

ការប្រើប្រាស់ប្រព័ន្ធកសិដ្ឋានទឹកបិទជិតនេះ ធ្វើឱ្យយើងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោមនេះ :

- វាអាចរក្សាបាននូវគុណភាពទឹកល្អ នៅក្នុងអាងបំប៉នកូន រហូតដល់ការប្រមូលផល
- គ្រាន់តែបន្ថែមទឹកភ្លាវ ១២ ភាគពាន់ ចូលបង្គ្រប់ទៅក្នុងអាងចម្រោះជីវសាស្រ្ត ជំនួសឱ្យបរិមាណទឹកក្នុងអាងបំប៉នកូននៅពេលបន្ទាប់ពីយើងបានធ្វើស៊ីហ្វុង

ឬបូមសម្អាតបាតអាងនោះរួច ដូច្នេះយើងឃើញថាប្រព័ន្ធកសិដ្ឋាននេះ ផ្តល់នូវប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ក្នុងការប្រើប្រាស់ទឹកសមុទ្រ បើប្រៀបធៀបទៅនឹងប្រព័ន្ធកសិដ្ឋានទឹកខៀវ ដោយប្រើរុក្ខជាតិប្លង់តុង ក្លរ៉េល្លា ឃើញថាចំណេញទឹកសមុទ្រចំនួន ១០ ដង។

ដើម្បីគ្រប់គ្រង ថែរក្សាប្រព័ន្ធកសិដ្ឋាននេះឱ្យបានល្អ យើងគួរត្រួតពិនិត្យជាប្រចាំ និងធ្វើគម្របប្រព័ន្ធទុយោបញ្ចេញទឹកចោលដោយប្រើក្រណាត់ស្បៃហាប៉ា។ ក្រណាត់ស្បៃហាប៉ានេះ ក៏យើងត្រូវតែធ្វើការដុសលាងសម្អាតជាប្រចាំផងដែរ ដើម្បីការពារការកកស្ទះដោយសម្រាម ឬ កាកសំណល់ផ្សេងៗ ដែលអាចបណ្តាលឱ្យស្ទះទឹកបញ្ចេញចោល។

ម្យ៉ាងទៀត យើងគួរមានការយកចិត្តទុកដាក់ និងឧស្សាហ៍ព្យាយាមបូមយកប៊ីតកាកសំណល់នៅបាតអាងបំប៉នកូន ជាពិសេស នៅពេលយើងឃើញមានសំណកកូនអាតេមីញ៉ាច្រើនអណ្តែតលើផ្ទៃទឹកអាង។

នៅពេលដែលយើងឃើញកូនបង្កងប្រមាណ ៥០ភាគរយ បានវិវដ្តដល់ដំណាក់កាលកូនម្ស៉ៅ (Post-larvae) នោះយើងត្រូវរៀបចំជម្រកធ្វើពីខ្សែសរសៃដាក់ចូលក្នុងអាងបំប៉នកូនបង្កងភ្លាមដើម្បីជៀសវាងការស៊ីគ្នា (រូបភាពទី ៧)។

នៅថ្ងៃទី ៣០ បន្ទាប់ពីកូនបង្កងញាស់ ឬ ថ្ងៃទី ៣០ នៃការបំប៉នកូនបង្កង បើសង្កេតឃើញថា មានកូនបង្កងភាគច្រើនបានវិវដ្តដល់ដំណាក់កាលកូនម្ស៉ៅ (Post - larvae) នោះ យើងត្រូវបញ្ឈប់ការប្រើប្រាស់ប្រព័ន្ធបិទជិត ហើយចាប់ផ្តើមដំណើរការកាត់បន្ថយកំហាប់អំបិលជាបណ្តើរៗពី ១២ ភាគពាន់ឱ្យធ្លាក់ចុះដល់ ២ ភាគពាន់។ នៅថ្ងៃទី ១ ត្រូវពង្រីងទឹកចេញពីអាងប្រមាណ ១/៤ នៃបរិមាណទឹកសរុបក្នុងអាងដោយធ្វើស៊ីហ្វុង រួចបញ្ចូលទឹកសាបបង្គ្រប់វិញឱ្យបានកំហាប់អំបិល ៨ ភាគពាន់។ នៅថ្ងៃទី ២ ត្រូវពង្រីងទឹកចេញពីអាងប្រមាណ ១/២ នៃបរិមាណទឹកសរុបក្នុងអាង

រួចបញ្ចូលទឹកសាបបង្គ្រប់វិញឱ្យបានកំហាប់អំបិល ៤ ភាគពាន់។

នៅថ្ងៃទី ៣ ត្រូវពង្រីងទឹកចេញពីអាងបន្ថែមទៀត ប្រមាណ ១/២ នៃបរិមាណទឹកសរុបក្នុងអាងរួចបញ្ចូលទឹកសាបបង្គ្រប់វិញឱ្យបានកំហាប់អំបិល ២ ភាគពាន់។ រហូតដល់ថ្ងៃទី ៤ យើងអាចធ្វើការផ្ទេរកូនបង្កងដែលបានវិវដ្តដល់ដំណាក់កាលមេៀ្យ ទាំងអស់ចូលទៅក្នុងទឹកសាបដើម្បីបំប៉នបន្ត។



រូបភាពទី៧: ខ្សែខ្មៅធ្វើជម្រក

## ៣.៥ ការប្រមូលផល

មុនពេលធ្វើការប្រមូលផលកូនបង្កងមេៀ្យ នោះជាបឋមយើងត្រូវប្រមូលខ្សែសរសៃ ដែលជាជម្រកទាំងអស់ចេញពីអាងដោយមានការប្រុងប្រយ័ត្ន បន្ទាប់មកពង្រីងទឹកចេញពីអាងប្រមាណ ៤០០ លីត្រ ដោយមានតម្រងច្រោះ ដើម្បីការពារកូនបង្កងចេញទៅក្រៅ។ បន្ទាប់មកទៀត កូនបង្កងត្រូវបានប្រមូលដោយប្រើកន្ត្រងស្បៃសម្រាប់ដួសយកទៅដាក់ក្នុងអាងទឹកមួយ មានដាក់ដុំខ្យល់ដែលបានរៀបចំរួចជាស្រេច ដើម្បីរាប់ចំនួនកូនបង្កងដោយការប៉ាន់ប្រមាណ។ កូនបង្កងត្រូវបានគេ រាប់ដោយវិធីសាស្ត្រថ្លឹង។

- ជាដំបូង យើងថ្លឹង ៣ គំរូ នៃចំនួនកូនបង្កង រួចរាប់ចំនួនកូនបង្កងនៅក្នុងគំរូនីមួយៗ (មុននឹងថ្លឹងកូនបង្កងត្រូវជូតទឹកឱ្យស្ងួត)។
- ធ្វើការគណនា ចំនួនកូនបង្កងក្នុង ១ ក្រាម នៃគំរូចំនួនកូនបង្កងនីមួយៗរួចគណនារកមធ្យមភាគ នៃគំរូចំនួនកូនបង្កងទាំងបីក្នុង ១ ក្រាម
- ចុងបញ្ចប់ យើងថ្លឹងកូនបង្កងទាំងអស់ដោយកន្ត្រងស្បៃ រួចធ្វើវិធីគុណ

ចំនួនកូនបង្កងជាមធ្យមក្នុង ១ ក្រាម។ គ្មានការធ្វើអង្កេតពីអត្រាបាត់បង់នោះទេ នៅក្នុងពេលប្រមូលផល និងការថ្លឹងកូនបង្កង។

ការប៉ាន់ប្រមាណជាមធ្យមពីអត្រាគង់វង្សរបស់កូនបង្កងគឺ ៦០% នៅក្នុងអាងបំប៉នចំណុះ ៥០០ លីត្រ នីមួយៗក្នុងករណីប្រើប្រាស់ប្រព័ន្ធកសិដ្ឋានបិទជិត។ មានន័យថា កូនបង្កងមេ្យវចំនួន ២០.០០០ ក្បាល បានមកពីការបំប៉នកូនបង្កងទើបញាស់ចំនួន ៣០.០០០ ក្បាល នៅក្នុងលក្ខខណ្ឌសីតុណ្ហភាព ចន្លោះពី ២៧អង្សាសេ ទៅ ៣១ អង្សាសេ។

## ៤. ការថែបំប៉នកូនបង្កងដល់ថ្ងៃទី ១៥

កូនបង្កងមេ្យវត្រូវបានគេយកវាទៅដាក់បំប៉ន នៅក្នុងអាងបំប៉នមួយផ្សេងទៀត ដើម្បីធ្វើការបំប៉នបន្តរហូតដល់វាមានអាយុ ១៥ ថ្ងៃ អាចលក់ចែកជូនដល់កសិករបាន។ ករណីខ្លះ យើងអាចធ្វើការបំប៉នបន្តរហូតដល់វាមានអាយុ ៤០ ថ្ងៃ។

### ៤.១ ប្រព័ន្ធអាងបំប៉ន

នៅក្នុងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាបបាទី យើងបានប្រើប្រាស់អាងស៊ីម៉ង់ត៍ដែលមានទំហំ ២ ម៉ែត្រ x ៣ ម៉ែត្រ រៀបចំនៅពីក្រោមដំបូលសម្រាប់បំប៉នកូនបង្កង។ នៅក្នុងប្រព័ន្ធអាងបំប៉នកូនបង្កងបញ្ចូលទឹកជម្រៅ ៦០ សង់ទីម៉ែត្រ ដាក់ថ្មខ្យល់ ចំនួន ៤ គ្រាប់ និងខ្សែរសរសៃធ្វើជាជម្រកចំនួន ១៥ បាច់ក្នុងមួយអាង មុនពេលលែងកូនបង្កងចូលអាងបំប៉ន។

### ៤.២ ដង់ស៊ីតេដាក់បំប៉ន ការផ្តល់ចំណី និងការគ្រប់គ្រងគុណភាពទឹក

កូនបង្កងត្រូវបានដាក់បំប៉នក្នុងកម្រិតដង់ស៊ីតេ ២០.០០០ ក្បាល ក្នុងអាង

ស៊ីម៉ង់ត៍ទំហំ ៦ ម៉ែត្រការ៉េ។ ការផ្លាស់ប្តូរទឹកថ្មីត្រូវបានធ្វើឡើងបន្ទាប់ពីដាក់កូនបង្កងបំប៉ន ក្នុងអាងរយៈពេល ៤ ថ្ងៃ នូវរៀងរាល់ ២ ថ្ងៃម្តង។ បរិមាណទឹកដែលត្រូវប្តូរប្រមាណ ៧០ ភាគរយ នៃចំណុះទឹកសរុបក្នុងអាង។ បាតអាងក៏ត្រូវបានធ្វើការសម្អាតដោយស៊ីហ្វុងចាប់ពីថ្ងៃទី ១០ តទៅ។

យើងបានផ្តល់ចំណីដល់កូនបង្កងចំនួនបីប្រភេទគឺចំណីកាស្តាត ចៃទឹក និង ចំណីគ្រាប់ (រូបភាពទី ៨)។



**រូបភាពទី ៨ កាស្តាត (រូបខាងឆ្វេង) ចៃទឹក (រូបកណ្តាល) និង ចំណីគ្រាប់កូនបង្កង (រូបខាងស្តាំ)**

**ការផ្តល់ចំណីកាស្តាត:** ប្រភេទចំណីនេះ បានផ្តល់ឱ្យកូនបង្កងចំនួន ២០.០០០ ក្បាល ស៊ីនូវកម្រិតបរិមាណ ២ ក្រាម ដោយកិននឹងកន្ត្រងស្បៃដែលមានក្រឡាទំហំ ១ មិល្លីម៉ែត្រ។

ការផ្តល់ប្រភេទចំណីនេះឱ្យកូនបង្កង ស៊ីបន្ទាប់ពីដាក់បំប៉នក្នុងអាងរហូតដល់ការប្រមូលផលដោយផ្តល់ចំនួន ៤ ដងក្នុងមួយថ្ងៃ គឺនៅម៉ោង ៧:៣០ ព្រឹក ម៉ោង ១០:០០ ព្រឹក ម៉ោង ២ រសៀល និង ម៉ោង ៤ ល្ងាច។

ចំណីផ្សំ ជាប្រភេទចំណីមួយផ្សំឡើងដោយសមាសធាតុមួយចំនួន ដែលមានសារធាតុចិញ្ចឹមខ្ពស់ តែនៅពេលយើងផ្តល់ឱ្យកូនបង្កងស៊ីជាលើកដំបូងនោះមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ រហូតដល់ពេលណាមួយកូនបង្កងមានលក្ខណៈបន្សាំទៅនឹងប្រភេទចំណីនេះទើបប្រែក្លាយទៅជាការល្អ។

**ការផ្តល់ចំណីចៃទឹក:** ចៃទឹកជាប្រភេទចំណីមានជីវិតមានកម្រិតប្រូតេអ៊ីនខ្ពស់ដែលជាប្រភេទចំណីល្អបំផុតសម្រាប់ឱ្យកូនបង្កងស៊ី។ បរិមាណចៃទឹកសម្រាប់ផ្តល់ឱ្យកូនបង្កងចំនួន ២០.០០០ ក្បាល ស៊ីក្នុងមួយថ្ងៃ គឺ ៥០០ ក្រាម ចំនួន មួយដងនៅ

ម៉ោង ៥ ល្ងាច ជារៀងរាល់ថ្ងៃ។ យើងត្រូវធ្វើការត្រួតពិនិត្យចំណីជា ប្រចាំបើករណី ឃើញមានចំណីនៅសល់ក្នុងទឹកនាថ្ងៃស្អែកបន្ទាប់នោះ យើងគួរកាត់បន្ថយបរិមាណ ចំណីសម្រាប់ផ្តល់ឱ្យកូនបង្កងស៊ីនៅថ្ងៃបន្តបន្ទាប់ទៀត ព្រោះថាចៃទឹកជាប្រភេទ ចំណីមួយដែលបង្កងចូលចិត្តស៊ីបំផុតហើយអាចបណ្តាលឱ្យកូនបង្កងឈប់ស៊ីប្រភេទ ចំណីផ្សេងៗទៀតដូចជាចំណីផ្សំ និងចំណីគ្រាប់។

**ការផ្តល់ចំណីគ្រាប់:** យើងបានប្រើប្រាស់ចំណីគ្រាប់ (កម្រិតប្រូតេអ៊ីន ៤០ ភាគរយ ជាប្រភេទចំណីគ្រាប់លិចទឹក) ដែលជាប្រភេទចំណីសម្រាប់ផ្តល់ឱ្យត្រីប្រាស៊ី យកមកជំនួសឱ្យកូនបង្កងស៊ីវិញ។ វិធីសាស្រ្តផ្តល់ចំណីដូចបង្ហាញជូនខាងក្រោមនេះ

- កូនបង្កងអាយុចាប់ពី ២ថ្ងៃ (PL-2) ឡើងទៅ ផ្តល់ចំណី ១ ក្រាម ក្នុងមួយថ្ងៃចំនួន ២ ដង នៅម៉ោង ៨:00 ព្រឹក និងម៉ោង ៤:៣0 នាទី ល្ងាច។
- កូនបង្កងអាយុចាប់ពី ៤ ថ្ងៃ (PL-4) ឡើងទៅគួរចាប់ផ្តើមបង្កើនបរិមាណចំណីឱ្យច្រើនជាង ១ ក្រាម ក្នុងមួយថ្ងៃ ។

តាមរយៈការធ្វើអង្កេតតាមដានឃើញថា កូនបង្កងស៊ីចំណីច្រើននៅពេលយប់តែស៊ីតិចនៅពេលថ្ងៃ។ ការផ្តល់ចំណីដល់កូនបង្កងឱ្យបានត្រឹមត្រូវ និងកាន់តែសុក្រឹតនោះ អាស្រ័យសំខាន់លើការតាមដាន និងពិនិត្យចំណីជាប្រចាំរបស់យើង។

**ជាឧទាហរណ៍:** ជាក់ស្តែងយើងបានផ្តល់ចំណីដល់កូនបង្កងនូវបរិមាណ ១.៥ ក្រាម នៅពេលព្រឹក និង ៣ ក្រាមនៅថ្ងៃរសៀល ចំពោះកូនបង្កងអាយុ ៧ ថ្ងៃ (PL-7) ឡើងទៅ។ ចំពោះកូនបង្កងមានអាយុចាប់ពី ១៥ ថ្ងៃ (PL-15) ឡើងទៅ បរិមាណចំណីដែលត្រូវផ្តល់ឱ្យវាស៊ីត្រូវបានបង្កើនឡើងខ្ពស់រហូតដល់ ៧ ក្រាម សម្រាប់ពេលព្រឹក និង ២0 ក្រាម នៅថ្ងៃរសៀល។

ជាធម្មតា នៅពេលកូនបង្កងមានអាយុ ១៥ ថ្ងៃ (PL-15) គឺជាខ្នាតកូនបង្កងអាចលក់ចេញបាន និងបំប៉នបន្តនៅក្នុងស្រះឱ្យក្លាយជាកូនពូជ។

ករណីយើងបំប៉នបន្តនៅក្នុងស្រះឱ្យក្លាយជាកូនពូជនោះ វិធីសាស្ត្រក្នុងការផ្តល់ចំណីត្រូវបានអនុវត្តដូចខាងក្រោមៈ

**ឧទាហរណ៍:** ជាក់ស្តែងយើងបានផ្តល់ចំណីដល់កូនបង្កងនូវបរិមាណ ៧ ក្រាម នៅពេលព្រឹក និង ២៦ ក្រាមនៅថ្ងៃរសៀលចំពោះកូនបង្កងអាយុ ២៥ថ្ងៃ (PL-25) ឡើងទៅ។ ចំពោះកូនបង្កងមានអាយុចាប់ពី ៤០ ថ្ងៃ (PL-40) ឡើងទៅបរិមាណចំណីដែលត្រូវផ្តល់ឱ្យវាស៊ីត្រូវបានបង្កើនឡើង និង ៤២ ក្រាម នៅថ្ងៃរសៀល។

## ៤.៣ ការប្រមូលផល និងដឹកជញ្ជូន

ការប្រមូលផល នឹងត្រូវបានដំណើរការធ្វើឡើងភ្លាម បន្ទាប់ពីបាន ពង្រីងអាង ឬស្រះរួចដោយប្រើអួនអូស ឬ កន្ត្រងស្បៃដួសដែលមានសាច់ក្រឡាល្អ។ បន្ទាប់មកទៀត យើងធ្វើការរាប់ចំនួនកូនបង្កងដោយប្រើរូបមន្តរាប់ ដូចបានជម្រាបជូនខាងលើ (ការប្រមូលផលក្នុងដំណាក់កាលបំប៉នកូនទើបញាស់)។

ជាទូទៅ កូនបង្កងមានអត្រាគង់វង្ស ៩០ ភាគរយ ចំពោះកូនមានអាយុ ១៥ ថ្ងៃ (PL-15) និងអត្រាគង់វង្សពី ៧០ ភាគរយ ទៅ ៨០ ភាគរយ ចំពោះកូនមានអាយុ ៥០ ថ្ងៃ (PL-50) ក្នុងលក្ខខណ្ឌសីតុណ្ហភាពចន្លោះពី ២៦ ទៅ ៣០ អង្សាសេ។

នៅក្នុងការដឹកជញ្ជូនកូនបង្កង យើងបានប្រើប្រាស់ថង់ប្លាស្ទិកទំហំ ៦០ សង់-ទីម៉ែត្រ x ១០០ សង់ទីម៉ែត្រ បញ្ចូលទឹកចំណុះ ១០ លីត្រ និងបញ្ចូលខ្យល់អុកស៊ី - ហ្សែន។ យើងអាចដាក់កូនបង្កងបានចំនួនចាប់ពី ៣០០០ ក្បាល ទៅ ៤.០០០ ក្បាល ក្នុងមួយថង់។